**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារលិខិតជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចតេជោ នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !**

នៅក្នុងឱកាសប្រារព្ធខួបកំណើតពិតរបស់ **សម្តេចតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី០៥ ខែ សីហា ឆ្នាំ១៩៥២- ០៥ ខែ សីហា ឆ្នាំ២០១៦ ដ៏ឧត្តុង្គឧត្តមនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្ញុំផ្ទាល់ សូមអភិវន្ទ សម្តែងនូវសេចក្តីអំណរសាទររីករាយ ជូនពរសព្ទសាធុការ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរ គ្រប់ប្រការជូន **សម្តេចតេជោ** នាយករដ្ឋមន្ត្រី ប្រកបដោយសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅនិងស្មោះស្ម័គ្របំផុត ចំពោះបញ្ញាញាណប្រកបដោយគតិបណ្ឌិត ដ៏ប្រពៃថ្លៃថ្លាក្នុងការដឹកនាំកសាង អភិវឌ្ឍមាតុភូមិកម្ពុជា មានសុខសន្តិភាពពេញលេញនិងរីកចម្រើនថ្កុំថ្កើងរុងរឿង។

ជាថ្មីម្តងទៀត នាឱកាសប្រារព្ធខួបកំណើតពិតដ៏នក្ខត្តឫក្សនេះ ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយថែរក្សា ការពារប្រោះព្រំ ជូន **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** ជាទីស្រឡាញ់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកឌឺហ្គោល សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ Generalsec@mod.gov.kh